ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA
Kingdom of Wonder

ក្រសួងទេសចរណ៍

លេខ ១៦៦ ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ សីហា ឆ្នាំ២០១៥

# ប្រកាស

## ស្តីពី

## គំរូស្លាកសញ្ញាចំណាត់ថ្នាក់សណ្ឋាគារ

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ មិថុនា ឆ្នាំ២០០៩ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ៣៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ២៦ អនក្រ.បក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០០ ស្តីពីការកែសម្រួលមុខងារ និងភារកិច្ច និងការបង្កើតក្រុមអ្នកច្បាប់ និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាននៃក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៤ ស្តីពីចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍
- យោងតាមតម្រូវការចាំបាច់នៃការងារ

អគារលេខ ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: +៨៥៥ ២៣ ៨៨៤ ៩៧៦ ទូរសារ: +៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website:www.mot.kh

# សម្រេច

**ប្រការ ១._**

ប្រកាសនេះមានគោលបំណងដាក់ចេញនូវគម្រូស្លាកសញ្ញាចំណាត់ថ្នាក់សណ្ឋាគារ ដូចមានក្នុងអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៤ ស្តីពីចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅ-ទេសចរណ៍។

**ប្រការ ២._**

ស្លាកសញ្ញាចំណាត់ថ្នាក់សណ្ឋាគារត្រូវអនុលោមតាមគំរូនៃឧបសម្ព័ន្ធដែលមានចែងក្នុងប្រកាសនេះ។

រាល់ចំណាយក្នុងការផលិតស្លាកសញ្ញាចំណាត់ថ្នាក់សណ្ឋាគារជាបន្ទុករបស់ម្ចាស់សណ្ឋាគារ។

**ប្រការ ៣._**

ការតាំង ឬផ្សព្វផ្សាយស្លាកសញ្ញាចំណាត់ថ្នាក់សណ្ឋាគារដែលមិនអនុលោមតាមគំរូដូចមានចែងក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ ត្រូវទទួលពិន័យទៅតាមច្បាប់ស្តីពីទេសចរណ៍ និងអនុក្រឹត្យលេខ១៦ អនក្រ.បក និងបទដ្ឋានគតិយុត្តិផ្សេងទៀតជាធរមាន។

**ប្រការ ៤._**

រាល់សណ្ឋាគារទាំងឡាយណា ដែលទទួលបានចំណាត់ថ្នាក់មុនកាលបរិច្ឆេទនៃប្រកាសនេះចូលជាធរមាន ត្រូវបន្តអនុវត្តទៅតាមគំរូនៃប្រកាសស្តីពីគំរូស្លាកសញ្ញាចំណាត់ថ្នាក់ចាស់រហូតដល់ថ្ងៃអស់សុពលភាពនៃចំណាត់-ថ្នាក់នោះ។

**ប្រការ ៥._**

ប្រកាសរបស់ក្រសួងទេសចរណ៍លេខ ១០៦ ប្រក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៩ ស្តីពីគំរូស្លាកសញ្ញាចំណាត់ថ្នាក់សណ្ឋាគារ ផ្កាយ១ ផ្កាយ២ ផ្កាយ៣ ផ្កាយ៤ ផ្កាយ៥ ត្រូវទុកជានិរាករណ៍។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ ៦._**

អគ្គនាយកទេសចរណ៍ អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ ប្រធានក្រុមអ្នកច្បាប់ អធិការ គ្រប់ប្រធាននាយកដ្ឋាន ប្រធានមន្ទីរទេសចរណ៍រាជធានី-ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រដ្ឋមន្ត្រី

ថោង ខុន

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- សាលារាជធានីខេត្ត
- សមាគមមគ្គុទ្ទេសក៍ទេសចរណ៍
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធ

## ស្តីពីគំរូស្លាកសញ្ញាចំណាត់ថ្នាក់សណ្ឋាគារ

## ប្រកាសលេខ១០៨ ប្រក..ចុះថ្ងៃទី១១.ខែ.សីហា.ឆ្នាំ២០១៥

### ១. ឧបសម្ព័ន្ធទី១÷ ស្តីពីគំរូស្លាកសញ្ញាចំណាត់ថ្នាក់សណ្ឋាគារ

ក្នុងបំណងពង្រឹងវិស័យឧស្សាហកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ និងងាយស្រួលដល់ភ្ញៀវទេសចរណ៍ សម្គាល់បានអំពីប្រភេទចំណាត់ថ្នាក់សណ្ឋាគារព្រះរាជាណាចក្រកម្ពុជា ក្រសួងទេសចរណ៍ សម្រេចកំណត់អំពីខ្នាត គំរូស្លាកសញ្ញាចំណាត់ថ្នាក់សណ្ឋាគារ ដូចខាងក្រោម៖

**១- វត្ថុធាតុដើមនៃស្លាកសញ្ញា**

- ផ្នែកស៊ុម : ទីបជ្រុងអាលុយមីញ៉ូម ១.៨សម
- ផ្នែកផ្ទៃខាងក្រោម : ធ្វើអំពីសន្លឹកអាគ្រីលិក កម្រាស់ ៣មម ពណ៌ស
- ផ្នែកផ្ទៃខាងលើ : ធ្វើអំពីសន្លឹកអាគ្រីលិកថ្លា កម្រាស់ ២មម
- ផ្នែកអក្សរHនិងផ្កាយផុស : ធ្វើអំពីសន្លឹកអាគ្រីលិក កម្រាស់ ៤មម ដោយមានសន្លឹកដែកពណ៌ទឹកមាស កម្រាស់ ០.៨មម រាងជាអក្សរ“H” ផ្កាយ និងនិមិត្តសញ្ញាបិទផ្នែកខាងលើ។

**២- ទម្រង់ស្លាកសញ្ញា:**

ទម្រង់ស្លាកសញ្ញារាងបួនជ្រុងទ្រវែងបញ្ឈរ

**៣- ទំហំស្លាកសញ្ញា:**

មានបណ្តោយ៤០.០០សម×ទទឹង៣០.០០សម

**៤- របៀបរចនាស្លាកសញ្ញា:**

ក- ផ្ទៃស្លាកសញ្ញា (ក្រៅពីផ្ទៃអក្សរ“H” រូបផ្កាយ ផ្ទៃអក្សរឈ្មោះសណ្ឋាគារ និងលេខសុពលភាព) គឺជាផ្ទៃអាគ្រីលិកដោយមានបិទរូបបោះពុម្ពរលោងជាក្បាច់ជញ្ជាំងថ្មអង្គរ

ខ- តួអក្សរផុស“H” តំណាងឲ្យសេវាសណ្ឋាគារ គឺជាផ្ទៃអាគ្រីលិកពណ៌សរ កម្រាស់ ៤មម ដោយមានបិទសន្លឹកដែកពណ៌ទឹកមាសនៅខាងលើ

គ- រូបផ្កាយផុសតំណាងឲ្យចំណាត់ថ្នាក់សណ្ឋាគារ គឺជាផ្ទៃអាគ្រីលិក កម្រាស់៤មម ដោយមានបិទសន្លឹកដែកពណ៌ទឹកមាសនៅខាងលើ

ឃ- តួអក្សរឈ្មោះសណ្ឋាគារ និងលេខសុពលភាពចំណាត់ថ្នាក់ជាផ្ទៃបោះពុម្ពរលោងមានពណ៌ទឹកប៊ិចស្រស់

ង- ផ្ទៃនិមិត្តសញ្ញាស្ថាប័ន គឺជាផ្ទៃអាគ្រីលិកកម្រាស់៤មមដោយមានបិទសន្លឹកដែកេពណ៌ទឹកមាសនៅខាងលើ

ច- តួអក្សរខ្មែរ “ក្រសួងទេសចរណ៍” ជាប្រភេទតួអក្សរឆ្លាក់លាបពណ៌ទឹកប៊ិចស្រស់

ឆ- តួអក្សរអង់គ្លេស “Ministry of Tourism” ជាប្រភេទតួអក្សរឆ្លាក់លាបពណ៌ទឹកប៊ិចស្រស់

ជ- រូបនិមិត្តសញ្ញាស្ថាប័ន គឺជាផ្ទៃឆ្លាក់លាបពណ៌ក្រហម និងពណ៌ទឹកប៊ិចស្រស់។

**៥- អំពីទំហំផ្ទៃស្លាកសញ្ញា តួអក្សរ និងរូបផ្កាយ :**

ក- ផ្ទៃផ្នែកខាងលើមានរូបថ្មជញ្ជាំងអង្គររលោង មានទំហំ ៣០០ មម×៣១០មម

ខ- តួអក្សរ“H” មានទំហំ ១២៥ មម×៩៥ មម

គ- រូបផ្កាយកំពូលប្រាំ ទំហំ ៤៥ មម×៤៥មម

ឃ- តួអក្សរឈ្មោះសណ្ឋាគារជាអក្សរឡាតាំង ទំហំអាចប្រែប្រួលទៅតាមចំនួនតួអក្សរតែត្រូវតូចជាងអក្សរ "H"

ង- លេខសុពលភាពឆ្នាំ ទំហំ ៥៥ មម×១០ មម

ច- ផ្ទៃផ្នែកខាងក្រោមសម្រាប់និមិត្តសញ្ញាក្រសួង ទំហំ ៣០០ មម×១១០ មម

ឆ- និមិត្តសញ្ញារបស់ស្ថាប័ន ចេញសេចក្តីសម្រេចទទួលស្គាល់ចំណាត់ថ្នាក់សណ្ឋាគារ រួមមានអក្សរ "ក្រសួងទេសចរណ៍" សរសេរជាភាសាខ្មែរ, អក្សរ "Ministry of Tourism" សរសេរជាភាសាអង់គ្លេស និងរូបនៃនិមិត្តសញ្ញាស្ថាប័ន មានទំហំសរុប ៨០ មម×៨០មម។

**៦. គម្លាតរវាងជួរនីមួយៗ**

**ក/ គម្លាតពីលើចុះក្រោម:**

- ពីគែមស្លាកខាងលើនៃស្លាកសញ្ញាដល់កំពូលតួអក្សរ "H" មានគម្លាត ៧០ មម
- ពីផ្នែកខាងក្រោមតួអក្សរ "H"ដល់ផ្នែកខាងលើរូបផ្កាយមានគម្លាត ៣៥ មម
- ពីផ្នែកខាងក្រោមរូបផ្កាយដល់ផ្នែកខាងលើអក្សរឈ្មោះសណ្ឋាគារមានគម្លាត ៣៥ មម
- ពីផ្នែកខាងក្រោមតួអក្សរឈ្មោះសណ្ឋាគារដល់ផ្នែកខាងលើលេខសុពលភាពមានគម្លាត ១០ មម
- ពីផ្នែកខាងក្រោមលេខឆ្នាំសុពលភាពដល់ផ្នែកខាងលើគែមនៃផ្ទៃសម្រាប់និមិត្តសញ្ញារបស់ស្ថាប័ន មានគម្លាត ១០ មម
- ពីគែមខាងលើនៃផ្ទៃខាងក្រោយសម្រាប់និមិត្តសញ្ញាស្ថាប័ន ដល់ផ្នែកខាងលើនិមិត្តសញ្ញារបស់ស្ថាប័ន ត្រង់តួអក្សរ "ក្រសួងទេសចរណ៍" មានគម្លាត ១៥មម
- ពីផ្នែកខាងក្រោមនៃនិមិត្តសញ្ញារបស់ស្ថាប័នត្រង់តួអក្សរ "Ministry of Tourism" ដល់គែមខាងក្រោមនៃស្លាកសញ្ញាមានគម្លាត ១៥មម។

**ខ/- គម្លាតពីគែមសងខាង:**

- តួអក្សរ "H" មានគម្លាតពីគែមខាងស្តាំ ៥០មម
- រូបផ្កាយនៅចន្លោះកណ្តាល និងមានគម្លាតពីគែមសងខាងអាស្រ័យលើចំនួនផ្កាយ
- តួអក្សរឈ្មោះសណ្ឋាគារនៅចន្លោះកណ្តាល និងមានគម្លាតពីគែមស្ពាន់សងខាងដោយអាស្រ័យលើប្រវែងនៃតួអក្សរ
- លេខសុពលភាពនៅចន្លោះកណ្តាល និងមានគម្លាតពីគែមសងខាង ១២២.៥ មម
- និមិត្តសញ្ញារបស់ស្ថាប័ននៅចន្លោះកណ្តាល និងមានគម្លាតពីគែមសងខាង ១១០ មម។

H

# NAME OF HOTEL

2015-2017

ក្រសួងទេសចរណ៍

MINISTRY OF TOURISM

# NAME OF HOTEL

2015-2017

ក្រសួងទេសចរណ៍

MINISTRY OF TOURISM

# NAME OF HOTEL

2015-2017

ក្រសួងទេសចរណ៍

MINISTRY OF TOURISM

H

★★★★

# NAME OF HOTEL

2015-2017

ក្រសួងទេសចរណ៍

MINISTRY OF TOURISM

H

★★★★★

**NAME OF HOTEL**

2015-2017

ក្រសួងទេសចរណ៍

MINISTRY OF TOURISM

## ២. ខ្ទង់សម្គាល់ទី២៖ ស្ទីគ័រ QR CODE សម្រាប់ស្លាកសញ្ញាចំណាត់ថ្នាក់សណ្ឋាគារ

QR CODE សម្រាប់គំរូស្លាកសញ្ញាចំណាត់ថ្នាក់សណ្ឋាគារ :

- QR CODE នេះមានបង្កប់ព័ត៌មានលម្អិតអំពីសណ្ឋាគារដែលទទួលចំណាត់ថ្នាក់។
- QR CODE នេះត្រូវបានបង្កើតឡើងក្នុងគោលបំណងធានានូវភាពស្របច្បាប់ និងភាពត្រឹមត្រូវនៃចំណាត់ថ្នាក់របស់សណ្ឋាគារដែលផ្តល់ដោយក្រសួងទេសចរណ៍។

ទី១- វត្ថុធាតុដើម :

រូបភាព QR CODE និងអក្សរ បោះពុម្ពនៅលើស្ទីកគ័រ (Sticker) រលោងពណ៌ស។

ទី២- ទីតាំង :

QR CODE ត្រូវបិទបង្កប់នៅពីក្រោយផ្នែកកណ្តាលនៃសន្លឹកគំរូស្លាកសញ្ញាចំណាត់ថ្នាក់។

ទី៣- ទំហំ :

QR CODE មានទំហំ ៣០មមX៣០មម។

ទី៤- ព័ត៌មានភ្ជាប់ :

នៅផ្នែកខាងស្តាំនៃរូប QR CODE មានព័ត៌មានសំខាន់ៗមួយចំនួនដូចជា៖

- ឈ្មោះសណ្ឋាគារ
- ចំណាត់ថ្នាក់សណ្ឋាគារ
- ទីតាំងសណ្ឋាគារ

## QR CODE សម្រាប់គំរូស្លាកសញ្ញាចំណាត់ថ្នាក់សណ្ឋាគារ

ប្រភេទគំរូស្លាកសញ្ញាចំណាត់ថ្នាក់សណ្ឋាគារថ្មីនេះ គឺមានបង្កប់នូវលេខ QR Code បិទនៅផ្នែកខាងក្រោយនៃសន្លឹកគំរូស្លាកសញ្ញាចំណាត់ថ្នាក់នេះ ។ QR Code នេះគឺជាមានបង្កប់នូវព័ត៌មានលំអិតទាក់ទងនឹងសណ្ឋាគារដែលទទួលបានចំណាត់ថ្នាក់ ។ ការបង្កប់នូវ QR Code នេះមានគោលបំណងដើម្បីធានានូវភាពស្របច្បាប់ និងភាពត្រឹមត្រូវនៃចំណាត់ថ្នាក់របស់ប្រតិបត្តិករសណ្ឋាគារដែលផ្ដល់ដោយស្ថាប័នមានសមត្ថកិច្ច ។

QR Code បង្ហាញនូវព័ត៌មានដូចជា:

-ឈ្មោះសណ្ឋាគារ

-ចំណាត់ថ្នាក់សណ្ឋាគារ

-ទីតាំងសណ្ឋាគារ




លេខ QR Code បិទនៅផ្នែកខាងក្រោយនៃសន្លឹកគំរូស្លាកសញ្ញា

